**អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា**

**Kampuchea Action to Promote Education (KAPE)**

# លិខិតជូនដំណឹង

- ពី : លោក សៅ វណ្ណា នាយកប្រតិបត្តិ អង្គការ ខេប
- ជូនចំពោះ : លោក/លោកស្រី ជាប្រធានក្រុមហ៊ុន ឬអាជីវករ និងអ្នកទទួលការផ្គត់ផ្គង់
- ចម្លងជូន : លោក សរ សុផាណាក់ ប្រធានគម្រោង IDEAL
  លោក ឈួន សារ៉ាន ប្រធានរដ្ឋបាល និងធនធានមនុស្ស
  លោក បូ សម្បត្តិ នាយកហិរញ្ញវត្ថុ
- កម្មវត្ថុ : ការបង់ប្រាក់កក់ធានារ៉ាប់រងសម្រាប់ចូលរួមដេញថ្លៃទទួលការផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យា នៅតាមសាលារៀនគោលដៅគម្រោង IDEAL។
- កាលបរិច្ឆេទ : ថ្ងៃសុក្រ ១៣រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤។

---

ដោយយោងទៅតាមគោលនយោបាយលទ្ធកម្មបានចែង និងអនុលោមតាមអនុសាសន៍របស់គណៈកម្មការក្រុមអ្នកគ្រប់គ្រងជាន់ខ្ពស់របស់អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា បានសម្រេចជាឯកច្ឆន្ទឱ្យក្រុមហ៊ុន/សហគ្រាស/សាជីវកម្ម ឬអាជីវករនិងអ្នកទទួលការផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យា ទាំងអស់ដែលមានសិទ្ធិចូលរួមដេញថ្លៃ តម្រូវឱ្យមានការបង់ប្រាក់កក់ធានារ៉ាប់រងដើម្បីចូលរួមដេញថ្លៃចំនួន **៥%** នៃចំនួនទឹកប្រាក់ដេញថ្លៃសម្ភារព័ត៌មានវិទ្យាសរុប បញ្ចប់ត្រឹមថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤ វេលាម៉ោង ៥:០០ល្ងាចជាកំហិត ដើម្បីមានសិទ្ធិចូលរួមបើកកញ្ចប់ដេញថ្លៃ។ ប្រសិនបើក្រុមហ៊ុន ឬអាជីវករ និងអ្នកទទួលការផ្គត់ផ្គង់ណាដែលមិនបានជាប់ក្នុងការដេញថ្លៃនោះទេ អង្គការនឹងបង្វែរប្រាក់កក់ទាំងអស់គ្រប់ចំនួនទៅឱ្យក្រុមហ៊ុន ឬអាជីវករ និងអ្នកទទួលការផ្គត់ផ្គង់វិញក្នុងរយៈពេលមួយសប្តាហ៍ក្រោយដេញថ្លៃរួច។

<u>សូមបញ្ជាក់ថា៖</u> ប្រសិនបើក្រុមហ៊ុន សហគ្រាស សាជីវកម្ម ឬអាជីវករ និងអ្នកទទួលការផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យាណាដែលមិនបានបង់ប្រាក់កក់ធានារ៉ាប់រងសម្រាប់ចូលរួមដេញថ្លៃ ៥% ខាងលើ អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា នឹងមិនអនុញ្ញាតឱ្យមានសិទ្ធិចូលរួមដេញថ្លៃ និងចូលរួមបើកកញ្ចប់ដេញថ្លៃនោះទេ ហើយកញ្ចប់ឯកសារដេញថ្លៃត្រូវចាត់ទុកជាអាសារបង់ និងនិរាករណ៍។

☺ អសយដ្ឋាន និងលេខគណនីធនាគារដែលត្រូវការបង់ប្រាក់កក់ធានារ៉ាប់រងមានលម្អិតដូចខាងក្រោម៖

១. ធនាគារ អេស៊ីលីដា (ACLEDA) សាខាខេត្ត កំពង់ចាម

- ឈ្មោះគណនី៖ KAPE SAVINGS
- លេខគណនី៖ 1000-20-151963-18

២. ធនាគារ អេប៊ីអេ (ABA) សាខាខេត្ត កំពង់ចាម

- ឈ្មោះគណនី៖ Kampuchea Action To Promote Education Organization
- លេខគណនី៖ 002 373 992

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ យើងខ្ញុំសង្ឃឹមទុកជាមុនថា លោក/លោកស្រី ជាម្ចាស់ក្រុមហ៊ុន សហគ្រាស សាជីវកម្ម ឬអាជីវករ និងអ្នកទទួលការផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យា ទាំងអស់មានការយោគយល់អធ្យាស្រ័យចំពោះសេចក្ដីជូនដំណឹងនេះ នឹងសង្ឃឹមថានឹងមានឱកាសជួបគ្នាក្នុងពេលឆាប់ៗខាងមុខតាមកាលបរិច្ឆេទកំណត់ ដើម្បីធ្វើការបើកកញ្ចប់ដេញថ្លៃការផ្គត់ផ្គង់សម្ភារព័ត៌មានវិទ្យាដាក់តាមសាលារៀនគោលដៅរបស់គម្រោង "លើកកម្ពស់ការអប់រំឌីជីថលសម្រាប់សិស្សានុសិស្ស"។

**សូមគោរព និងសូមអរគុណ**!

**អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា**

**នាយកប្រតិបត្តិ**

KAMPUCHEA ACTION TO PROMOTE EDUCATION ORG.

សៅ.វណ្ណា